**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តបន្ទាយមានជ័យ**
លេខ៖..............✓.....................

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលខេត្តបន្ទាយមានជ័យ សូមជម្រាបជូនដំណឹងដល់សាធារណជន បងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារយោធាថៃហ៊ុំព័ទ្ធដីធ្លីនៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងអ្នកសារព័ត៌មានទាំងអស់ឱ្យបានជ្រាបថា ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យមានបងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារយោធាថៃហ៊ុំព័ទ្ធបន្លាលួស ដាក់ទូកុងតឺន័រយកដីធ្លី ផ្ទះសម្បែងដែលមិនអាចចូលទៅរស់នៅលើទីតាំងដីរបស់ខ្លួនបានមានដូចជាភូមិជោគជ័យ ភូមិព្រៃចាន់ ស្ថិតនៅឃុំអូរបីជាន់ ស្រុក-អូរជ្រៅ និងភូមិសាមគ្គី ភូមិត្រពាំងសំពេង ភូមិផ្លូវបំបែក និងភូមិបន្ទាយមានឫទ្ធិ ស្ថិតនៅឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តែងតែគិតគូរ និងយកចិត្តទុកដាក់ខ្ពស់ទាំងការរស់នៅ និងជីវភាពរបស់បងប្អូនដែលរងផលប៉ះពាល់ដោយសារយោធាថៃហ៊ុំព័ទ្ធផ្ទះសម្បែង ហើយបាននិងកំពុងរៀបចំដីធ្លីជាគម្រោងរបស់សមាគមអតីតយុទ្ធជន ដើម្បីសាងសង់ផ្ទះសម្រាប់ផ្តល់ជូនបងប្អូនដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងតំបន់ហ៊ុំព័ទ្ធបានរស់នៅជាបណ្តោះអាសន្ន ដែលមានទីតាំងនៅភូមិស្លក្រាម ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ លើផ្ទៃដីទំហំ៤០០ហិកតា និងមានហេដ្ឋារចនាសម្ព័ន្ធនានាគ្រប់គ្រាន់ ហើយបច្ចុប្បន្ន ក្រុមការងារបាននិងកំពុងដំណើរការសាងសង់ផ្ទះបានមួយចំនួន និងផ្តល់ជូនសម្រាប់បងប្អូនភៀសសឹក ដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងតំបន់ហ៊ុំព័ទ្ធចូលទៅរស់នៅជាបណ្តោះអាសន្ន ទៅតាមជំហានៗ តាមរយៈនៃការចាប់ឆ្នោតយកលេខក្បាលដីឡូត៍។

ថ្មីៗនេះក្រុមការងាររៀបចំដីឡូត៍បានរៀបចំកម្មវិធីចាប់ឆ្នោតយកផ្ទះ និងដីឡូត៍ជូនជនភៀសសឹក ដើម្បីចូលទៅរស់នៅបណ្តោះអាសន្ន ប៉ុន្តែនៅមានបងប្អូនជនភៀសសឹកមួយចំនួនដែលបានចុះឈ្មោះក្រោយជាបន្តបន្ទាប់ ហើយពុំទាន់ទទួលបានផ្ទះ និងដីឡូត៍មានការព្រួយបារម្ភខ្លាចអត់ទទួលបានផ្ទះ និងដីឡូត៍។ រដ្ឋបាលខេត្តបន្ទាយមានជ័យ សូមបញ្ជាក់ជូនថា ការដោះស្រាយជូនបងប្អូនជនភៀសសឹកដែលមានដី និងផ្ទះសម្បែងដែលមិនអាចចូលទៅរស់នៅបានដោយសារយោធាថៃហ៊ុំព័ទ្ធបន្លាលួស ដាក់ទូកុងតឺន័រក្នុងភូមិសាស្ត្រភូមិខាងលើ ហើយការរៀបចំស្របតាមបែបបទ និងនីតិវិធីទៅតាមការចុះឈ្មោះរបស់បងប្អូនជនភៀសសឹក។

អាស្រ័យដូចបានបញ្ជាក់ជូនខាងលើនេះ សូមបងប្អូនប្រជាពលរដ្ឋពាក់ព័ន្ធ សាធារណជន និងអ្នកសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៦រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
បន្ទាយមានជ័យ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០២៦

អាសយដ្ឋាន: ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ
(Phone-Fax) ០៥៤ ៧១០០៦២ Email: banteaymeanchey1@gmail.com ,
Web: www.bmc.ncdd.gov.kh , www.facebook.com/adminbmcs , Telegram: 012 673086 / 078 266866